

# រឿង កូនផ្ទះតុក្កតា

Mut Somaly

Seat Sopheap

Let's Read
The Asia Foundation



កាលពីព្រេងនាយ មានមិត្តភក្តិបីនាក់គឺ កូនផ្ទះមួយឈ្មោះ ទូទូ បន្ទាត់ឈើមួយឈ្មោះ ពីពី និង ខ្មៅដៃមួយឈ្មោះ ម៉ាម៉ូ។ ពួកគេរស់នៅយ៉ាងរីករាយនៅក្នុងបន្ទប់គេងរបស់ក្មេងស្រីម្នាក់។



ថ្ងៃមួយ បន្ទាត់ឈើបង្វិលខ្លួន រួចនិយាយទៅកាន់ ខ្មៅដៃថា៖ " នែ ម៉ាម៉ូ ឯងមានសង្កេតឃើញទេថា ស្នាមក្រិតទាំងសងខាង លើខ្លួនខ្ញុំខុសគ្នា?" ខ្មៅដៃ ម៉ាម៉ូ ក៏លាន់មាត់ថា៖ "អូ! គួរឲ្យ ចាប់អារម្មណ៍មែន!" បន្ទាប់មក ខ្មៅដៃ ក៏ឱនមើលខ្លួនវា។ "អេ ខ្ញុំគិតថាថ្ងៃនេះខ្លួនខ្ញុំ ដូចជាខ្លីជាងពីម្សិលមិញ។ តើឯងគិតដូច ខ្ញុំទេ?"



”ទូទូ តើឯងគិតយ៉ាងម៉េចដែរ?” ពួកគេសួរកូនផ្ទះតូច។ កូនផ្ទះទូទូ ក៏ដកដង្ហើមធំ ធ្វើមុខស្រពោន។ តាមពិតវាអាចធ្វើអ្វីបានលើសពី ពីពី និង ម៉ាម៉ូ អាចធ្វើបានទៅទៀត។ ប៉ុន្តែវាមិនអាចបង្វិល ឬ កាច់រាងដូចមិត្តទាំងពីរបានទេ។ ដូច្នេះវាមិនដឹងថាខ្លួនវាមានរាងបែប ណាឡើយ!



ពីពី និង ម៉ាម៉ូ ក៏ព្យាយាមធ្វើឲ្យ ទូទូ សប្បាយចិត្ត។ ពួកគេខំបោសសម្អាតធូលីតាមជញ្ជាំង និងដំបូល។ ម៉ាម៉ូ លេងហ្គីតារ ពីពី ច្រៀងបទសប្បាយៗ ប៉ុន្តែ ទូទូនៅតែមិនសប្បាយចិត្ត។



ពីពី និង ម៉ាម៉ូ ក៏ពិភាក្សាគ្នា។ ពីពី និយាយ៖ ”មើលទៅ ទូទូ ពិបាកចិត្តខ្លាំងណាស់។ ខ្ញុំឆ្ងល់ណាស់ថា មូលហេតុអ្វីបានជា...” ម៉ាម៉ូ ក៏លើកឡើងថា៖ ”ខ្ញុំគិតថា ប្រហែល ជាគេពិបាកចិត្តដោយសារមិនដឹងខ្លួនឯងមានរាងយ៉ាងម៉េចហើយ។” ”ត្រូវហើយ! យើងអាចជួយគេបាន!” ពីពី និយាយ។



ពីពី និង ម៉ាម៉ូ ក៏ដើរទៅរក ទូទូ ដើម្បីរៀបរាប់ប្រាប់ពីរូបរាងរបស់វា។ ម៉ាម៉ូ ប្រាប់ថា ដំបូល ទូទូ មានរាងត្រីកោណដែលមានបីជ្រុង។ ពីពី រៀបរាប់ថា ជញ្ជាំងរបស់ ទូទូ មានរាងចតុកោណកែង ហើយមានទំហំខុសៗគ្នា។ ប៉ុន្តែ ទូទូ នៅតែមិនដឹងថាខ្លួនវាមានរាងយ៉ាងណាឲ្យប្រាកដ។ វានៅតែតូចចិត្ត។



ឃើញដូច្នេះ ពីពី និង ម៉ាម៉ូ ក៏មានគំនិតថ្មីមួយ។ ពួកគេទៅយកកញ្ចក់រាងមូលតូចមួយមក។ ម៉ាម៉ូ ស្រែកប្រាប់៖ ”ទូទូមើលនែ! ឥឡូវអាចមើលឃើញរាងខ្លួនឯងហើយឬនៅ?” ប៉ុន្តែដោយសារកញ្ចក់តូចពេក ទូទូ នៅតែមិនអាចមើលរាងខ្លួនឯងបានដដែល។



បន្ទាប់មក ពីពី ក៏មានគំនិតល្អមួយ។ ពីពី លាន់មាត់៖ ”អាហា! យើងអាចគូររូប ទូទូ បាន!” ម៉ាម៉ូ យល់ស្របៈ ”ត្រូវហើយ! ប៉ុន្តែខ្ញុំមានបញ្ហាដោយមិនអាច គូសបន្ទាត់ត្រង់បានទេ។” ”ខ្ញុំអាចជួយបានទេតើ។ តោះ ធ្វើជាមួយគ្នា!” ពីពី ឆ្លើយ។



ពីពី ផ្ដេកខ្លួនលើផ្ទាំងក្រដាសធំមួយ។ ម៉ាម៉ូ ក៏ ចាប់ផ្ដើមគូរ
បន្ទាត់ត្រង់តាមជ្រុងរបស់ ពីពី។ បន្ទាប់មកពួកគេក៏រួមគ្នាគូ
បន្ទាត់ពីរបន្ថែម ទៀត រហូតដល់បានជារាងត្រីកោណ។ អូហូ!
មើលទៅដូចជាដំបូលរបស់ ទូទូ!



ពីពី និយាយ៖ ”អស្ចារ្យ! ឥឡូវគោះគូររាងចតុកោណកែង សម្រាប់ជញ្ជាំងខាងមុខ។ បន្ទាប់មកយើងនឹងគូររាង ចតុកោណកែងតូចមួយទៀតជាទ្វារ និងបង្អួចរាងជាការ៉េ។”



ម៉ាមូ និយាយ៖ "អីយ៉ា! មើលទៅដូច ទូទូ ណាស់!" "ត្រូវហើយ ប៉ុន្តែដូចជាខ្វះអ្វីម្យ៉ាង។" ពីពី ឆ្លើយ។ "ខ្ញុំដឹងហើយ!" និយាយរួច ម៉ាម៉ូ ក៏គូររង្វង់មូលមួយលើផ្ទះ។ ពីពី លាន់មាត់៖ "មែនហើយ! គឺភ្លេចរូបព្រះអាទិត្យ!"



ពីពី និង ម៉ាម៉ូ ក៏កាន់រូបនោះទៅរក ទូទូ ម្តងទៀតដោយត្រេកអរ។ ”ទូទូ មើលនែ! មើលរូបផ្ទះនេះទៅមើល៍ មានដំបូលរាងត្រីកោណ ជញ្ជាំង និងទ្វាររាងចតុកោណកែង និងបង្អួចរាងការ៉េ។ គឺរូបឯងហ្នឹងហើយ!!!” ទូទូ ក៏ចាប់ផ្តើមញញឹមជាលើកដំបូង បន្ទាប់ពីមុខស្រពោនអស់ជាច្រើនថ្ងៃ។ ”ពិតមែនឬ? នេះជារូបរាងខ្ញុំមែនទេ?” ទូទូ និយាយដោយត្រេកអរ។ ”គឺឯងមែនណា!” ពីពី បញ្ជាក់។ ”ហើយយើងបានថែមរូបព្រះអាទិត្យ មួយទៀតផង!” ម៉ាម៉ូ និយាយបន្ថែម។



កូនផ្ទះ ទូទូ អរគុណដល់មិត្តទាំងពីរគឺបន្ទាត់ឈើ ពីពី និង ខ្មៅដៃ ម៉ាម៉ូ សម្រាប់រូបភាពមួយនេះ។ ពីពេលនោះមក ពួកគេក៏រស់នៅជាមួយគ្នាយ៉ាងសប្បាយរីករាយ។



តើនៅជុំវិញខ្លួនអ្នកមានរបស់អ្វីខ្លះដែលអ្នកអាចគូរបានដោយប្រើរាងធរណីមាត្រងាយៗដូចជា ត្រីកោណ ចតុកោណ និងរង្វង់មូល?

**រឿង ផ្ទះតុក្កតា**

សមាជិកក្រុមហាក់កាសុន៖ **មុត សុម៉ាលី** (អ្នកនិពន្ធ) **សៀត សុភាព** (វិចិត្រករ) **លឹម អេងគាត** (អ្នករចនា)។

សូមថ្លែងអំណរគុណជាពិសេសដល់ ហ៊ុយ ឆេងរតនា សឿម កក្កដា ជូ ជីនិត និងក្រុមការងារ CamAnt Technology ចំពោះការជួយគាំទ្រដល់កម្មវិធីហាក់កាសុន សៀវភៅអេឡិចត្រូនិច តោះអាន! ដែលបានធ្វើឡើងក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩ និង ២០ ខែ សីហា ឆ្នាំ ២០១៧។

©មូលនិធិអាស៊ីឆ្នាំ២០១៨។ រក្សាសិទ្ធិមួយចំនួន។ ស្នាដៃនេះត្រូវបានការពារក្រោមអាជ្ញាប័ណ្ណប្រភេទ Creative Commons Attribution-NonCommercial 4.0 (http://creativecommons.org/licenses/by-nc/4.0/)។ អ្នកអាច ចែករំលែក (ថតចម្លង និងចែកចាយបន្តឯកសារនេះ ដោយមធ្យោបាយ ឬក្នុងទម្រង់អ្វីក៏បាន) ដោយសេរី និងធ្វើការកែសម្រួល (លាយបញ្ចូលជាមួយឯកសារផ្សេងទៀត បម្លែង និងបង្កើតជាឯកសារថ្មីផ្សេងទៀត) ស្នាដៃនេះសម្រាប់គោលបំណងមិនមែនពាណិជ្ជកម្ម។ អ្នកចេញអាជ្ញាប័ណ្ណមិនអាចដកហូតសេរីភាពទាំងនេះបានឡើយ ដរាបណាអ្នកគោរពទៅតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណដូចខាងក្រោម៖

សេចក្ដីថ្លែងអំណរគុណ-អ្នកត្រូវសរសេរពីប្រភពឯកសារឲ្យបានសមស្រប បង្ហាញពីតំណភ្ជាប់ទៅកាន់អាជ្ញាប័ណ្ណ និងបញ្ជាក់ពីការផ្លាស់ប្ដូរឯកសារ ប្រសិនបើមាន។ អ្នកអាចធ្វើបែបនេះ តាមវិធីណាក៏បានដែលសមស្រប ប៉ុន្តែពុំមានន័យថា អ្នកផ្ដល់អាជ្ញាប័ណ្ណគាំទ្រដល់អ្នក ឬដល់ការប្រើប្រាស់របស់អ្នកនោះទេ។

មិនមែនលក្ខណៈពាណិជ្ជកម្ម-អ្នកមិនអាចប្រើប្រាស់ឯកសារនេះ សម្រាប់គោលបំណងពាណិជ្ជកម្មឡើយ។

**The Dollhouse**

Hackathon team: **Mut Somaly** (Writer), **Seat Sopheap** (Illustrator), **Lim Engkeat** (Graphic Designer).

Special thanks to Huy Chheng Rattana, Soeurm Kakada, Chou Chinith, and the CamAnt Technology team for their help with the Let's Read! E-book Hackathon, which took place in Phnom Penh on 19 and 20 August 2017.

© The Asia Foundation, 2018. Some rights reserved. This work is licensed under a Creative Commons Attribution-NonCommercial 4.0 Licence (http://creativecommons.org/licenses/by-nc/4.0/). You are free to share (copy and redistribute the material in any medium or format) and adapt (remix, transform, and build upon the material) this work for any non-commerical purpose. The licensor cannot revoke these freedoms as long as you follow the following license terms:

Attribution — You must give appropriate credit, provide a link to the license, and indicate if changes were made. You may do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.

NonCommercial — You may not use the material for commercial purposes.

Generously Supported By

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*រឿង កូនផ្ទះតុក្កតា (The Dollhouse)*, Author: Mut Somaly. Illustrator: Seat Sopheap. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC-BY-NC-4.0.